ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លេខ : ១៥៧ អ/ អភ-ក

ភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

# អគ្គនាយកសុរិយោដី និង ភូមិសាស្ត្រ

## ជំរាបមក

## ប្រធានមន្ទីរ.ដនសស ខេត្ត តាកែវ កំពត កំពង់ធំ និងក្រុងព្រះសីហនុ

**កម្មវត្ថុ** : ស្តីពីការបញ្ជូនសំណុំឯកសារ Pre_LMAP ដែលមានលក្ខណៈមិនគ្រប់គ្រាន់ និងពុំទាន់ចេញប័ណ្ណ ទៅមន្ទីរ ដនសស ដើម្បីបំពេញសំណុំបែបបទ និងធ្វើការចេញប័ណ្ណជូនម្ចាស់កម្មសិទ្ធិករ ។

**យោង** :
- ចំណារឯកភាពឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការចាត់បញ្ជូនសុំណុំឯកសារគំរោងសាកល្បងដែលពុំត្រឹមត្រូវ និងពុំទាន់ចេញប័ណ្ណ ដល់ខេត្ត-ក្រុងទាំង ៤ ដើម្បីធ្វើការចេញប័ណ្ណជូន ។
- លិខិតលេខ ១៧ ន/អភិ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីអំពីរបាយការណ៍បាត់ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

តបតាមកម្មវត្ថុ និង យោងខាងលើ អគ្គនាយកដ្ឋានសូមជំរាបមកលោកប្រធានមន្ទីរ ដនសស អនុវត្តគំរោង Pre_LMAP ជ្រាបថា : នាយកដ្ឋានអភិរក្សសុរិយោដី បានបញ្ចប់ដំណើរការរៀបចំទុកដាក់ឯកសារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរបស់ខេត្ត-ក្រុង អនុវត្តគំរោង Pre_ LMAP ចំនួន ៤ មាន : ខេត្តតាកែវ, ខេត្តកំពត, កំពង់ធំ និង ក្រុងព្រះសីហនុ ដែលមាន ១៣ ឃុំ ស្មើនឹង ៦២ ភូមិ ដែលមានក្បាលដីសរុបចំនួន ៤៩១៤៥ ក្បាលដី ក្នុងនោះមានក្បាលដីនៅសល់ និងពុំទាន់ចេញប័ណ្ណសរុបចំនួន ៣៤០៨ ក្បាលដី ដែលត្រូវចាត់បញ្ជូនទៅខេត្ត-ក្រុងសាម៉ីទាំង ៤ ដើម្បីបំពេញសំណុំបែបបទបន្ថែម និង ធ្វើការចេញប័ណ្ណ ក្នុងនោះមាន ខេត្ត តាកែវ ១២៦៨ ក្បាលដី, ក្រុងព្រះសីហនុ ១០៣២ ក្បាលដី, ខេត្តកំពត ៦០០ ក្បាលដី និង ខេត្តកំពង់ធំ ចំនួន ៥០៨ ក្បាលដី ។

( សូមជូនភ្ជាប់ តារាងសរុប និងតារាងលំអិត នៃចំនួនក្បាលដី និង ក្បាលដីដែលបាត់ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី របស់ខេត្ត-ក្រុងទាំង៤ )

សំណុំឯកសារដែលនៅសល់ទាំងនេះ អគ្គនាយកដ្ឋានពិនិត្យឃើញថា មានឯកសារដែលត្រូវបោះបង់ចោល ចំនួន ២៤៧៦ សំណុំឯកសារ ដោយខ្វះឯកសាររលុប និងមិនមានលក្ខណៈគ្រប់គ្រាន់, ក្បាលដីមានប័ណ្ណ